Health Plan of San Joaquin
Mountain Valley Health Plan
7751 S. Manthey Rd | French Camp, CA 95231
1-888-936-PLAN (7526) TTY 711
www.hpsj-mvhp.org

08/18/2025

ជូនចំពោះសមាជិកជាទីគោរព

នៅពេលអ្នកក្លាយជាសមាជិក យើងបានផ្ញើកូនសៀវភៅភស្តុតាងនៃការធានារ៉ាប់រង (EOC) មកអ្នក។ យើងចង់ប្រាប់អ្នកអំពីការផ្លាស់ប្តូរចំពោះ EOC របស់អ្នក៖

- **ផ្នែកទី 3 –** របៀបទទួលបានការថែទាំ៖ សេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រមនៅក្រោមការថែទាំរសើប

សូមរក្សាទុកព័ត៌មានថ្មីៗទាំងនេះជាមួយ EOC របស់អ្នក។ អ្នកក៏អាចស្វែងរកព័ត៌មានថ្មីៗនេះនៅលើគេហទំព័ររបស់យើងផងដែរតាម www.hpsj-mvhp.org។

**យើងនៅរង់ចាំជួយអ្នកជានិច្ច!**

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការជំនួយទាក់ទងនឹងអត្ថប្រយោជន៍របស់អ្នក សូមទូរសព្ទទៅលេខ **1-888-936-PLAN (7526) TTY 711 ថ្ងៃចន្ទ – សុក្រ ម៉ោង 8 ព្រឹកដល់ 5 ល្ងាច។ ការហៅទូរសព្ទគឺឥតគិតថ្លៃ។**

ប្រសិនបើអ្នកមានបញ្ហា ឬសំណួរដែលគម្រោងថែទាំសុខភាព Health Plan of San Joaquin/ Mountain Valley Health Plan មិនអាចជួយអ្នកបាន អ្នកអាចទូរសព្ទទៅការិយាល័យទទួលបណ្តឹងពលរដ្ឋ តាមលេខ **1-888-452-8609** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ម៉ោង 8:00 ព្រឹក – 5:00 ល្ងាច ដោយមិនរាប់បញ្ចូលថ្ងៃឈប់សម្រាក។ អ្នកដែលមានបញ្ហាពិបាកក្នុងការស្តាប់ និងការនិយាយអាចប្រើប្រាស់លេខទូរសព្ទឥតគិតថ្លៃរបស់សេវាបញ្ជូនបន្តរដ្ឋកាលីហ្វ័រញ៉ា (TTY) តាមរយៈលេខ **1-800-735-2929.**

ដោយក្តីគោរព

គម្រោងថែទាំសុខភាព Health Plan of San Joaquin/Mountain Valley Health Plan

# 3. របៀបទទួលបានការថែទាំ

## ការថែទាំរសើប

### សេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រម

ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកមិនត្រូវការការអនុញ្ញាតពីមាតាបិតា ឬអាណាព្យាបាលដើម្បីទទួលបានសេវាថែទាំសុខភាពមួយចំនួន ហើយអ្នកអាចទទួលវាដោយសម្ងាត់ ដែលមានន័យថាមាតាបិតា ឬអាណាព្យាបាលរបស់អ្នកនឹងមិនត្រូវបានគេជូនដំណឹង ឬទាក់ទងទេ ប្រសិនបើអ្នកទទួលសេវាកម្មទាំងនេះ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។ សេវាកម្មទាំងនេះត្រូវបានគេហៅថា សេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រម។

អ្នកអាចទទួលបានសេវាខាងក្រោម នៅអាយុក្រោម 12 ឆ្នាំ៖

- សេវាសម្រាប់ករណីរំលោភបំពានផ្លូវភេទ
- សេវាសម្រាប់ពេលមានផ្ទៃពោះ និងទាក់ទងនឹងការមានផ្ទៃពោះ
- សេវារៀបចំផែនការគ្រួសារ ដូចជាសេវាពន្យារកំណើត (ឧ. ថ្នាំពន្យារកំណើត)

បន្ថែមពីលើសេវាកម្មដែលបានរាយខាងលើ អ្នកក៏អាចទទួលបានសេវាកម្មខាងក្រោមនៅ **អាយុ 12 ឆ្នាំឡើងទៅ៖**

- ការព្យាបាល ឬការប្រឹក្សាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺសម្រាកក្រៅមន្ទីរពេទ្យ។ វានឹងអាស្រ័យលើភាពចាស់ទុំ និងសមត្ថភាពរបស់អ្នកក្នុងការចូលរួមក្នុងការថែទាំសុខភាពរបស់អ្នក ដូចដែលបានកំណត់ដោយអ្នកជំនាញ
- ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺឆ្លង រោគឆ្លង ឬជំងឺឆ្លងរាតត្បាត រួមទាំងមេរោគអេដស៍/ជំងឺអេដស៍
- ការបង្ការ ការធ្វើតេស្ត ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ (STI) សម្រាប់ជំងឺកាមរោគដូចជា ស្វាយ ប្រមេះទឹកបាយ ប្រមេះទឹកថ្លា និងជំងឺអែរប៉េស
- សេវាសម្រាប់អំពើហិង្សាពីដៃគូស្នេហា

- ការព្យាបាលបញ្ហាប្រើប្រាស់សារធាតុញៀន (SUD) ទាក់ទងនឹងការប្រើគ្រឿងញៀន និងគ្រឿងស្រវឹង រួមមានសេវាពិនិត្យ វាយតម្លៃ អន្តរាគមន៍ និងបញ្ជូនបន្ត

អ្នកអាចទទួលបានសេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រមពីអ្នកផ្តល់សេវា Medi-Cal ឬគ្លីនិកណាមួយក៏បាន។ អ្នកផ្តល់សេវាមិនចាំបាច់នៅក្នុងបណ្តាញរបស់ Health Plan ទេ។ អ្នកមិនត្រូវការការបញ្ជូនបន្តពី PCP របស់អ្នក ឬការយល់ព្រមជាមុន (ការអនុញ្ញាតជាមុន) ទេ។

ប្រសិនបើអ្នកប្រើអ្នកផ្តល់សេវាក្រៅបណ្តាញសម្រាប់សេវាកម្មដែល**មិន**ទាក់ទងនឹងសេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រម នោះពួកគេប្រហែលជាមិនត្រូវបានធានារ៉ាប់រងទេ។

ដើម្បីស្វែងរកអ្នកផ្តល់សេវា Medi-Cal នៅក្រៅបណ្តាញ Medi-Cal របស់ Health Planសម្រាប់សេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រម ឬដើម្បីស្នើសុំជំនួយធ្វើដំណើរដើម្បីទៅជួបអ្នកផ្តល់សេវា សូមទូរសព្ទទៅសេវាអតិថិជនរបស់ Health Plan តាមលេខ
1-888-936-PLAN (7526), TTY 711។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាពន្យារកំណើត សូមអានផ្នែក "សេវាបង្ការ និងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ" នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។

Health Plan មិនរ៉ាប់រងសេវាដែលអនីតិជនអាចទទួលបានដោយគ្មានការយល់ព្រម ដែលជាសេវាសុខភាពផ្លូវចិត្តឯកទេស (SMHS) ឬសេវា SUD ភាគច្រើនទេ។ ខោនធីដែលអ្នករស់នៅរ៉ាប់រងលើសេវាទាំងនេះ។ ដើម្បីស្វែងយល់បន្ថែម រួមទាំងរបៀបទទួលបានសេវាទាំងនេះ សូមអានផ្នែក "សេវាសុខភាពផ្លូវចិត្តឯកទេស (SMHS)" និង "សេវាព្យាបាលបញ្ហាប្រើប្រាស់សារធាតុញៀន (SUD)" នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។ ដើម្បីស្វែងយល់បន្ថែម សូមទូរសព្ទទៅ 1-888-936-PLAN (7526), TTY 711។

ដើម្បីទទួលបានបញ្ជីលេខទូរសព្ទឥតគិតថ្លៃរបស់ខោនធីទាំងអស់សម្រាប់សេវាសុខភាពផ្លូវចិត្តឯកទេស (SMHS) សូមចូលទៅកាន់៖
http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx

ដើម្បីទទួលបានបញ្ជីលេខទូរសព្ទឥតគិតថ្លៃរបស់ខោនធីទាំងអស់សម្រាប់សេវាព្យាបាល SUD សូមចូលទៅកាន់៖
https://www.dhcs.ca.gov/individuals/Pages/SUD_County_Access_Lines.aspx។

អនីតិជនអាចនិយាយជាមួយតំណាងដោយឯកជនអំពីបញ្ហាសុខភាពរបស់ពួកគេ ដោយទូរសព្ទទៅខ្សែទូរសព្ទសម្រាប់ពិគ្រោះជាមួយគិលានុបដ្ឋាយិក 24/7 តាមលេខ 1-800-655-8294, TTY 711។

អ្នកអាចស្នើសុំដើម្បីទទួលបានព័ត៌មានឯកជនអំពីសេវាវេជ្ជសាស្ត្ររបស់អ្នកក្នុងទម្រង់ ឬទ្រង់ទ្រាយជាក់លាក់មួយ ប្រសិនបើមាន។ អ្នកអាចផ្ញើវាទៅអ្នកនៅទីតាំងផ្សេងបាន។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបស្នើសុំការទំនាក់ទំនងជាសម្ងាត់ដែលទាក់ទងនឹងសេវារសើប សូមអានផ្នែក "សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព" នៅក្នុងជំពូកទី 7 នៃសៀវភៅណែនាំនេះ។